00003067

~~D312.2.6~~
00003067
E3/116

# សេចក្តីអំពាវនាវរបស់ ខៀវ សំផន ហ៊ូ យន់ ហ៊ូ និម
# ចំពោះ
# ព្រះសង្ឃ និងបងប្អូនជនរួមជាតិនៅទីក្រុងភ្នំពេញ និងទីរួមខេត្តផ្សេងៗទៀត ដែលខ្មាំងកាន់កាប់បណ្តោះអាសន្ន

*ព្រះសង្ឃគ្រប់ព្រះអង្គជាទីគោរព!*

*បងប្អូនជនរួមជាតិអ្នករដ្ឋការគ្រប់ប្រភេទជាទីស្នេហា!*

*បងប្អូនទាហាននៅក្នុងកងទ័ពខ្មាំងទាំងឡាយ!*

*ស្ថានការណ៍អាក្បត់លន់ ណុល សិរីមតៈ ស៊ឺងង៉ុកថាញ់ និងបក្សពួកវាកំពុងចាញ់ខ្លាំងនិងដុនដាបជាទីបំផុត លើគ្រប់សមរភូមិយោធា នយោបាយ សេដ្ឋកិច្ច ហើយកំពុងអត់អន្ទរយ៉ាងធ្ងន់ធ្ងរណាស់ ៗ សភាពនេះវានឹងរិតតែធ្ងន់ធ្ងរទៅទៀតជាដាច់ខាតគ្មានច្រកណាចេញរួចទេ ៗ កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិយើងវាយសម្រុកគ្រប់ទិសទី ពិសេសតាមផ្លូវយុទ្ធសាស្ត្រលេខ១ លេខ២ និងលេខ៥ វាយសង្កត់ខ្លាំងជាប់ជុំវិញភ្នំពេញ និងផ្តាច់ភ្នំពេញពីគ្រប់ទីកន្លែង ធ្វើឲ្យសំបុកចុងក្រោយបង្អស់របស់ខ្មាំងនេះកំពុងស្លុរឈាម រកខ្យល់ដកមិនទាន់ ៗ ដូច្នោះខាងយោធាវារិតតែចាញ់ធ្ងន់ទៅទៀត ហើយអន្ទរវារិតតែអស់រលីងទៅទៀត គ្មានអ្វីមកដោះទស្រាយបានទេ ៗ អំពីបញ្ហាអន្ទរនេះ សូមព្រះអង្គនិងបងប្អូនអ្នករដ្ឋការទាហានស៊ីវិលទាំងអស់ជ្រាបថាៈ ច្បាស់ជារលីងគ្មាន១គ្រាប់ហើយពេលនេះនិងអនាគត ៗ បក្សពួកអាក្បត់ភ្នំពេញដែលមានអាលន់ ណុល សិរីមតៈ ស៊ឺងង៉ុកថាញ់ជាមេ គ្មានសម្ថភាពអ្វីបន្តិចបន្តួចដោះស្រាយប្រគេនព្រះសង្ឃនិងជូនបងប្អូនទេ វាមានតែយកកាំភ្លើងនិងច្បាប់ហ្វាស៊ីសរបស់វាមកសម្លាប់ព្រះអង្គនិងបងប្អូនទៀត ចក្រពត្តអាមេរិកចៅហ្វាយធំវា និងពួកអាធីវគីក៏ដូចជាពួកអនុចៅហ្វាយវាផ្សេងទៀតក៏ជួយវាមិនរួចទោះជាអាណុលអាថាញ់ ទៅសំពះបាទជើងវាយ៉ាងណាក៏ដោយ ៗ ពួកអាទាំងនេះកំពុងជាប់ដៃនិងចាញ់នៅវៀតណាមខាងត្បូង ៗ ចំពោះសភាពធ្ងន់ធ្ងរបំផុតយ៉ាងនេះ ដែលប៉ះទៅដល់អាយុជីវិតនៃឈ្លបពួកអាក្បត់បច្ចុប្បន្ន ពួកអាក្បត់ក្រោមបញ្ជាបៃចក្រពត្តិអាមេរិកមានតែទុកឲ្យព្រះអង្គដាច់ចង្ហាន់ និងបងប្អូនស្លាប់ដោយដាច់ពោះ ឬបាញ់សម្លាប់ព្រះសង្ឃនិងបងប្អូន កាលណាព្រះសង្ឃនិងបងប្អូនគិតគូររកអង្ករច្រកឆ្នាំងនេះ ៗ បទបញ្ជារបស់អាណុល និងរបស់អគ្គបញ្ជាការវាទៅថ្ងៃទី៨-៩កញ្ញា ១៩៧២នេះជាភស្តុតាងស្រាប់ ៗ*

*ក្នុងសភាពការណ៍ខ្មាំងចាញ់ធ្ងន់គ្រប់មុខយ៉ាងនេះហើយ ទាល់ច្រកទាំងស្រុងយ៉ាងនេះ កងកម្លាំង*

ប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ក្នុងសន្ទុះជ័យជំនះរបស់ខ្លួនកំពុងបន្តវាយសម្រុកខ្មាំងយ៉ាងខ្លាំងក្លាជាទូរទៅ ហើយកំពុងសង្កត់ភ្នំពេញក្នុងសភាពជាន់ខ្លាំងជាប់ ៗ ដូច្នេះក្នុងនាមរណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាដែលក្តាប់ជាប់សភាពការណ៍ជាក់ស្តែងនៅសមរភូមិទូទាំងប្រទេស ក្តាប់ជាប់នូវសភាពការណ៍ភ្នំពេញ បច្ចុប្បន្នក្តាប់ជាប់សភាពការណ៍ដកចង្កាមាន់របស់ខ្មាំង និងក្តាប់ជាប់សភាពម្ចាស់ការណ៍វាយសម្រុកដូចរន្ទះរបស់កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជានាបច្ចុប្បន្ននេះយើងខ្ញុំៈ

ខៀវ សំផន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារប្រទេស ហ៊ូ យន់ រដ្ឋមន្ត្រីក្រសួងឃោសនាការនិងព័ត៌មាននៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាសូមអំពាវនាវជាបន្ទាន់ដល់ៈ ព្រះសង្ឃគ្រប់ បងប្អូនជនរួមជាតិ បងប្អូនអ្នករដ្ឋការ ទាហានស៊ីវិលទាំងអស់នៅភ្នំពេញនិងនៅទីរួមខេត្តខ្លះទៀតខ្មាំងកាន់កាប់បណ្តោះអាសន្ន សូមសាមគ្គីជាធ្លុង១ ជាមួយប្រជាជននិងកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាៈ

១) តស៊ូវាយឃ្លាំងអង្ករ ឃ្លាំងស្បៀងទាំងអស់ដែលមាន ដើម្បីជាចង្ហាន់ព្រះអង្គ និងបំពេញក្រពះបងប្អូន ៗ

២) តស៊ូវាយពួកអាក្បត់ធំៗគឺ អាលន់ ណុល អាសិរីមតៈ អាស៊ឺងង៉ុកថាញ់ អាអ៊ិនតាំ អាលន់ ណុន អាហង់ធុនហាក់ និងអាក្បត់ឯទៀតឲ្យវារលំរលាយទាំងស្រុង ទាំងខ្លួនវា ទាំងបរិវារនៅពេលនេះ ៗ

៣) សូមព្រះអង្គនិងបងប្អូនប្រើកម្លាំងសាមគ្គីរបស់ព្រះអង្គនិងបងប្អូន ទាំងអាវុធគ្រប់បែប កាំភ្លើងធំតូច កាំបិតដំបងដែលសម្លាប់ពួកអាក្បត់ឲ្យសូន្យកុំឲ្យវាបន្ទាន់សម្លាប់ជាតិ សម្លាប់ព្រះអង្គនិងបងប្អូនតទៅទៀត ៗ

៤) ក្នុងករណីចាំបាច់សូមព្រះអង្គ បងប្អូនមិត្តនិងដកថយមកតំបន់រំដោះជុំវិញភ្នំពេញដើម្បីបន្តការវាយខ្មាំងតទៅទៀតជាមួយប្រជាជននិងកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជារហូតដល់បានជ័យជំនះទាំងស្រុង ៗ នៅតំបន់រំដោះមានអង្ករ មានចង្ហាន់ និងមានបាយហូបគ្រប់គ្រាន់ ៗ

សូមព្រះអង្គនិងបងប្អូនក្រោកឡើងវាយកម្ទេចអាខ្មាំងតំបន់រំដោះថ្ងៃ៩កញ្ញា១៩៧២ ៗ

ខៀវ សំផន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារប្រទេស

ហ៊ូ យន់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម កែទម្រង់ជនបទនិងសហករណ៍

ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងឃោសនាការនិងព័ត៌មាន នៃរដ្ឋាភិបាលរួបរួមជាតិកម្ពុជា

**ដកស្រង់ចេញពីសៀវភៅកំណត់ហេតុរបស់ ឈ្មោះ ហេង**

**ដោយ ហ៊ុយ វណ្ណៈ**